**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែវិច្ឆិកា និងទិសដៅការងារខែធ្នូ ឆ្នាំ២០២២

*នៅក្នុងខែវិច្ឆិកានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារលើគ្រប់វិស័យ ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដោយទទួលបានលទ្ធផលដូចខាងក្រោម៖*

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖

### ១- មុខងារតាមដានការអនុវត្តច្បាប់

*-បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងកិច្ចប្រជុំពិភាក្សាការងារជូនគណៈកម្មការទី១ព្រឹទ្ធសភា ជាមួយគណៈកម្មការទី១ និងគណៈកម្មការទី៣ នៃរដ្ឋសភា, ក្រសួងបរិស្ថាន, ក្រសួងការពារជាតិ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគណៈកម្មាធិការសម្រាប់អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៃក្រសួងមហាផ្ទៃ លើសំណើរបស់តំណាងសហគមន៍ជនជាតិភាគតិច១៦អំបូរ ក្នុងការកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពី តំបន់ការពារធម្មជាតិ និងសេចក្តីព្រាងច្បាប់ស្តីពី ព្រៃឈើ។*

### ២-មុខងារតំណាង

**-បានរៀបចំចាត់ចែង ផ្តល់សេវា និងអមដំណើរ៖**

**+សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា៖**

- *អញ្ជើញចូលរួមព្រះរាជកម្មពិធី "១០០ព្រះវស្សានៃព្រះបិតាឯករាជ្យជាតិ" ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត* ***ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី*** *ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង* ***សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ*** *ព្រះវររាជមាតាជាតិខ្មែរ នៅសាលមហោស្រពចតុមុខមង្គល*

- អញ្ជើញជាគណៈអធិបតីដង្ហែព្រះរាជដំណើរ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុតក្នុងព្រះរាជពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៦៩ នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២២ នៅវិមានឯករាជ្យ
- អញ្ជើញជាគណៈអធិបតីដង្ហែព្រះរាជដំណើរ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុតក្នុងព្រះរាជពិធីពន្លត់ទៀនជ័យ នៅវិមានឯករាជ្យ
- អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខមន្ត្រី អាជ្ញាធរ និងកងកម្លាំងប៉ុស្តិ៍នគរបាល នៅខេត្តពោធិ៍សាត់
- អញ្ជើញសួរសុខទុក្ខលោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី ប៊ូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ ព្រឹទ្ធសភា នៅគេហដ្ឋាន ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

**+ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុម កា អនុប្រធានទី១ ព្រឹទ្ធសភា៖**

- អញ្ជើញចូលរួមព្រះរាជកម្មពិធី "១០០ព្រះវស្សានៃព្រះបិតាឯករាជ្យជាតិ" ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ នៅសាលមហោស្រពចតុមុខមង្គល។

**+ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ព្រឹទ្ធសភា៖**

- អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ថ្វាយកម្រងផ្កា និងគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** និងបុព្វការីជនក្នុងឱកាសនៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២២ នៅវិមានឯករាជ្យ
- អញ្ជើញជាកិត្តិយសក្នុងពិធីបើក និងបិទកីឡាជាតិ លើកទី៣ ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** នៅពហុកីឡដ្ឋានជាតិមរតកតេជោ រាជធានីភ្នំពេញ
- អញ្ជើញដឹកនាំក្រុមសមាជិកាព្រឹទ្ធសភា រៀបចំពិធីដាល់អំបុក អកអំបុក និងបណ្តែតប្រទីបដើម្បីអបអរសាទរក្នុងឱកាសនៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ

អកអំបុក នៅក្រុងតាខ្មៅ។

+ថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញជាគណៈអធិបតី និងជាកិត្តិយស ក្នុងព្រះរាជពិធីប្រទានភ្លើងជ័យ និងពន្លត់ទៀនជ័យក្នុងឱកាសបុណ្យខួបអនុស្សាវរីយ៍ លើកទី៦៩ នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២២ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណា ព្រះបាទសម្តេចព្រះ-បរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅវិមានឯករាជ្យ។

+គណៈកម្មការទី៧ព្រឹទ្ធសភា អញ្ជើញចូលរួមវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី៣ នៅមហោស្រពចេនឡា រាជធានីភ្នំពេញ និងអញ្ជើញប្រគល់ផ្ទះ១ខ្នង ជូនលោក **ជិន មាន** ជាគ្រួសារក្រីក្រ នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។

+លោកជំទាវប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំគណៈកម្មការទ្រទ្រង់មូលនិធិគន្ធបុប្ផាកម្ពុជានៃព្រឹទ្ធសភា ក្នុងគោលបំណងកៀរគរថវិកាដើម្បីចូលរួមចំណែកក្នុងការជួយទ្រទ្រង់មូលនិធិគន្ធបុប្ផាកម្ពុជា។

+គណៈកម្មការទី៩ព្រឹទ្ធសភាអញ្ជើញចូលរួមក្នុងពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង/ស្រុក ក្រុមប្រឹក្សាឃុំ/សង្កាត់ មន្ត្រីរាជការ និងកម្លាំងប្រដាប់អាវុធ នៅខេត្ត-ពោធិ៍សាត់។

+ឯកឧត្តមប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា៖

- អញ្ជើញជាគណៈអធិបតីបើកសិក្ខាសាលាវាយតម្លៃហានិភ័យនៃការកើតភាពមិនប្រក្រតីក្នុងវិស័យសុខាភិបាល នៅសណ្ឋាគារសូហ្វីតែល រាជធានីភ្នំពេញ
- ជាតំណាងដ៏ខ្ពង់ខ្ពស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** នាំយកបរិក្ខារពេទ្យ ឱសថ ឧបករណ៍ សម្ភារវេជ្ជសាស្ត្រ សម្លៀកបំពាក់ និងសម្ភារប្រើប្រាស់ដែលជាអំណោយរបស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ ប្រគល់ជូនមន្ទីរពេទ្យបង្អែកខេត្តកំពង់ស្ពឺ មន្ទីរពេទ្យបង្អែកគងពិសី មន្ទីរពេទ្យបង្អែកឧត្តុង្គ មន្ទីរពេទ្យបង្អែកភ្នំស្រួច មណ្ឌលកុមារកំព្រារដ្ឋ មណ្ឌលកុមារកំព្រាជ្រៃជុំ សមាគមផ្ទះជាក្រុមភូមិរបស់យើង មណ្ឌលបណ្តុះបណ្តាល និងថែរក្សាសុខភាព នៅខេត្តកំពង់ស្ពឺ។

+សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ អាណត្តិទី៥ ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខ សណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយភូមិ-ឃុំមាន សុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ សម្ភោធសមិទ្ធផលនានា ដោះស្រាយទុក្ខលំបាករបស់ ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ជាពិសេសពិនិត្យដំណើរការចុះឈ្មោះបោះឆ្នោត និង អំពាវនាវឱ្យប្រជាពលរដ្ឋទៅពិនិត្យ និងចុះឈ្មោះបោះឆ្នោតឱ្យបានគ្រប់ៗគ្នា នៅតាម មូលដ្ឋានរៀងៗខ្លួនក្នុងភូមិភាគទាំង៨ ចំនួន៩០លើក។

-បានធ្វើបទបង្ហាញស្តីពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា ជូនសិស្សមន្ត្រីជាន់ខ្ពស់ និង កម្មសិក្សាការី នៃសាលាភូមិន្ទរដ្ឋបាល ដែលចូលរួមផ្ទាល់ចំនួន១៤២នាក់ និងតាមប្រព័ន្ធវីដេអូចំនួន ៤៧៩នាក់

-បានផ្តល់សេវាជូនក្រុមការងាររបស់**ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា** ចុះសួរសុខទុក្ខ និងនាំយកថវិកាមួយចំនួនជូនឯកឧត្តម **ញៀន គឿន** រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ដែលមានជំងឺស្ទះសរសៃឈាមខួរក្បាល និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ ដោរ៉ែភ្នំពេញ ព្រមទាំងអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ចុះទៅពិនិត្យ និងព្យាបាលជំងឺជូន ប្រជាពលរដ្ឋ នៅខេត្តកណ្តាល និងខេត្តបន្ទាយមានជ័យ

-បានចាត់ចែងបញ្ជូនសារលិខិតអបអរសាទររបស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** គោរពជូន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង ជាប្រធានអាស៊ានឆ្នាំ២០២២ ដែលទទួលបានជោគជ័យយ៉ាងត្រចេះត្រចង់ក្នុងការរៀបចំកិច្ចប្រជុំកំពូល អាស៊ានលើកទី៤០ និងលើកទី៤១

-បានចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនឥស្សរជនជាន់ខ្ពស់តាម ក្រសួង ស្ថាប័ននានាចំនួន០៣លិខិត

-បានរៀបចំ និងផ្ញើសាររំលែកទុក្ខជូនគ្រួសារសពមន្ត្រីជាន់ខ្ពស់ចំនួន០១លើក

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅនៅបណ្ណាល័យ ព្រឹទ្ធសភាចំនួន១៦នាក់

-បានផលិត និងផ្សព្វផ្សាយទស្សនាវដ្តីប្រចាំខែវិច្ឆិកា ឆ្នាំ២០២២ ចំនួន៨០០ក្បាល

-បានបោះពុម្ពសៀវភៅទិនានុលេខន៍ព្រឹទ្ធសភាឆ្នាំ២០២៣ចំនួន២,៨០០ក្បាល និងសៀវភៅបត់ស្តីពី សមាសភាព តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់គណៈកម្មការទាំង១០ព្រឹទ្ធសភាចំនួន១,០០០សន្លឹក

-បានទទួលពាក្យបណ្តឹងចំនួន០៦ករណី បញ្ជូនពាក្យបណ្តឹងទៅក្រសួង រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន០៧ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៧ករណី កំពុងពិនិត្យសិក្សាចំនួន០៥ករណី ទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការចំនួន០១ករណី។

**៣-មុខងារសហប្រតិបត្តិការអន្តរជាតិ**

-បានរៀបចំចាត់ចែង និងផ្តល់សេវាជូន **សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា៖**

+ក្នុងពិធីជំនួបសម្តែងការគួរសម និងសវនាការជាមួយឯកឧត្តម Jagdeep Dhankhar អនុប្រធានាធិបតីនៃសាធារណរដ្ឋឥណ្ឌា និងជាប្រធានព្រឹទ្ធសភា, ឯកឧត្តម Rachid Talbi EL Alami ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រម៉ារ៉ុក, លោកជំទាវ Sahiha Ali Gizi Gafarova ប្រធានសភានៃសាធារណរដ្ឋអាស៊ែបៃហ្សង់, ឯកឧត្តមបណ្ឌិត **សាយ សំផន ភូមិវិហាន** ប្រធានរដ្ឋសភានៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ, ឯកឧត្តម **វឿង ឌីញហ្វេ** ប្រធានរដ្ឋសភា និងឯកឧត្តម **ផាម មិញជីញ** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងគណៈប្រតិភូ

+អញ្ជើញថ្លែងសុន្ទរកថាក្នុងពិធីបើកមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ (AIPA-43) ក្រោមមូលបទ "បោះជំហានជាមួយគ្នា ដើម្បីចីរភាព បរិយាប័ន្ន និងភាពធន់របស់អាស៊ាន" នៅសណ្ឋាគារសុខាភ្នំពេញ

+អញ្ជើញជាកិត្តិយសក្នុងព្រះរាជពិធីលៀងសាយភោជន៍ថ្វាយ **ព្រះចៅស៊ុលតង់** HAJI HASSANAL BOLKIAH ព្រះមហាក្សត្រនៃប្រទេសព្រុយណេ និងព្រះរាជគណៈប្រតិភូ រៀបចំឡើងដោយ**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅព្រះបរមរាជវាំង

+អញ្ជើញជាអធិបតីក្នុងពិធីជប់លៀងអាហារសាមគ្គី ជូនជាកិត្តិយសដល់ប្រធានរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅអគារវឌ្ឍនៈ។

-បានរៀបចំចាត់ចែង និងផ្តល់សេវាជូន **ឯកឧត្តមកិត្តិសង្គហបណ្ឌិត ខេត ឯន អនុប្រធានទី២ព្រឹទ្ធសភា៖**

+ក្នុងពិធីជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម Konstantin Kosachev អនុប្រធានក្រុមប្រឹក្សាសហព័ន្ធ និងជាប្រធានគណៈប្រតិភូនៃសហព័ន្ធរុស្ស៊ី និងឯកឧត្តម **ផាម មិញជីញ** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

+អញ្ជើញជាអធិបតីក្នុងពិធីលៀងសាយភោជន៍ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា បណ្តាប្រទេសសមាជិកអាយប៉ា និងអ្នកអង្កេតការណ៍ជាតិ-អន្តរជាតិ នៅសណ្ឋាគារសុខាភ្នំពេញ។

-បានរៀបចំចាត់ចែងជូនសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមកិច្ចប្រជុំអន្តរជាតិ និងកម្មវិធីផ្សេងៗ រួមមាន៖ អញ្ជើញចូលរួមប្រជុំមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ (ASEAN Inter-Parliamentary Assembly) ក្រោមមូលបទ "បោះជំហានជាមួយគ្នា ដើម្បីចីរភាព បរិយាប័ន្ន និងភាពធន់របស់អាស៊ាន" ក្រោមអធិបតីភាព**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** និងជាប្រធានមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៤៣ នៅសណ្ឋាគារសុខាភ្នំពេញ, កិច្ចប្រជុំក្រុមការងារទទួលបន្ទុកការសើរើលក្ខន្តិកៈនៃសភាប្រើភាសាបារាំង និងចូលរួមមហាសន្និបាតប្រចាំឆ្នាំនៃបណ្តាញក្រុមសីលធម៌សមាជិកសភាប្រើភាសាបារាំង នៅសាធារណរដ្ឋបារាំង, ទស្សនកិច្ចការងារនៅសភាសហព័ន្ធវ៉ាល់ឡូនី ព្រុចសែល ព្រះរាជាណាចក្របែលហ្ស៊ិក, កិច្ចប្រជុំប្រចាំឆ្នាំនៃវេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិក លើកទី៣០ (APPF-30th) នៅព្រះរាជាណាចក្រថៃឡង់ដ៍, មហាសន្និបាតសភាប្រើភាសាបារាំង (APF) តំបន់អាស៊ី-ប៉ាស៊ីហ្វិក លើកទី១០ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម, កិច្ចប្រជុំក្រុមទទួលបន្ទុកសហប្រតិបត្តិការជាមួយសហភាពអន្តរសភាកម្ពុជា ដឹកនាំដោយ ឯកឧត្តម **កែប ជុតិមា** ប្រធានគណៈកម្មការទី៤នៃរដ្ឋសភា ដើម្បីត្រៀមលក្ខណៈចូលរួមកិច្ចប្រជុំក្រុមទទួលបន្ទុកសហប្រតិបត្តិការជាមួយសហភាពអន្តរសភាលើកទី១០ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម នៅវិមានរដ្ឋសភា, កិច្ចប្រជុំត្រៀមរៀបចំខ្លឹមសារ និងឯកសារពាក់ព័ន្ធនានា ដើម្បីទទួលគណៈប្រតិភូបេសកកម្មសុឆន្ទៈនៃសភាប្រើភាសាបារាំង ដែលគ្រោងមកទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជីមហ៊ុយ** ប្រធានក្រុមសមាជិកព្រឹទ្ធសភា ទទួលបន្ទុកសហប្រតិបត្តិការជាមួយសភានិយាយភាសាបារាំងនៅវិមានព្រឹទ្ធសភា, ចូលរួមក្នុងពិធីពិព័រណ៍ Walking through a songline រៀបចំឡើងដោយស្ថានទូតអូស្ត្រាលី ប្រចាំព្រះរាជាណាចក្រកម្ពុជា

-បានផ្តល់សេវាជូនសមាជិកព្រឹទ្ធសភា អញ្ជើញជួបសំដែងការគួរសម និងពិភាក្សាការងារជាមួយ ឯកឧត្តម **Mohamad SALHAJRI** ឯកអគ្គរាជទូតគុយវ៉ែត ទើបតែងតាំងថ្មី ប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីរឹតចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងសភា និងប្រជាជននៃប្រទេសទាំងពីរ កម្ពុជា-គុយវ៉ែត នៅស្ថានទូតគុយវ៉ែត ប្រចាំព្រះរាជាណាចក្រកម្ពុជា

-បានរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU)ស្តីពី កិច្ចសហ-ប្រតិបត្តិការរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជាជាមួយខុទ្ទកាល័យរដ្ឋសភានៃសាធារណរដ្ឋ-

សង្គមនិយមវៀតណាម

- បានរៀបចំជំនួយស្មារតី សុន្ទរកថា ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា សម្រាប់ពិធីជួបសវនាការជាមួយគណៈប្រតិភូជាន់ខ្ពស់សភានៃប្រទេសជាមិត្ត និងពិធីបើកមហាសន្និបាតអន្តរសភាអាស៊ាន(AIPA) លើកទី៤៣

- បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតចិន, ស្ថានទូតសិង្ហបុរី, ស្ថានទូតម៉ាឡេស៊ី, ស្ថានទូតព្រុយណេ, ស្ថានទូតឥណ្ឌា, ស្ថានទូតថៃ, អង្គការតម្លាភាពកម្ពុជា(TI Cambodia), មូលនិធិសន្តិភាពដើម្បីអភិវឌ្ឍ, ក្រុមប្រឹក្សាអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា(CDC), មជ្ឈមណ្ឌលសភាអាស៊ី(PCA), វិទ្យាស្ថានSunrise, វិទ្យាស្ថានជាតិស្ថិតិ(NIS), វិទ្យាស្ថានGreatX Center, វិទ្យាស្ថានSalaCyber, វិទ្យាស្ថានMUT International College, វិទ្យាស្ថានProseth, ភ្នាក់ងារសង្គមព័ត៌មានជាតិ(NIA), សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន, បណ្ណាល័យអាស៊ី-អឺរ៉ុប, ក្រុមហ៊ុនKOHA, ក្រុមហ៊ុន Cambodia Hosting និងក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ជំនួយ ព្រមទាំងការរៀបចំពិធីផ្សេងៗ។

**៤-មុខងារអភិវឌ្ឍន៍ស្ថាប័ន**

- បានទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម **លី រស្មី** រដ្ឋលេខាធិការក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យលើគម្រោងប្លង់របនាផ្នែកខាងក្នុងនៃសាលនានាក្នុងអគារក្រហម និងប្លង់សាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាថ្មី នៅវិមានព្រឹទ្ធសភា

- បានរៀបចំធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទម្រង់ថ្មី ជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា

- បានប្រជុំត្រួតពិនិត្យពិភាក្សាការងារសំខាន់ៗ និងលើកទិសដៅការងារសម្រាប់អនុវត្តបន្តរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានប្រជុំការងារលទ្ធកម្មនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានប្រជុំត្រៀមបើកវគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ

- បានផ្សព្វផ្សាយសេចក្តីជូនដំណឹងដល់សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភាស្តីពី ការចូលរួមបំពេញកាតព្វកិច្ចបរិច្ចាគជូនមូលនិធិគន្ធបុប្ផាសម្រាប់ឆ្នាំ២០២២

- បានដំណើរការបំពេញឯកសារប្រកាសទ្រព្យសម្បត្តិសម្រាប់ឆ្នាំ២០២៣។

**៤.១-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ**

-បានបើកប្រាក់បៀវត្សប្រចាំខែវិច្ឆិកា ឆ្នាំ២០២២ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានតាមដានគោលការណ៍ និងព័ត៌មានថ្មីទាក់ទងនឹងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

-បង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល

-បានរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗ និងកំណត់បង្ហាញចំនួន០៧ច្បាប់

-បានធ្វើប័ណ្ណសម្គាល់ខ្លួនមន្ត្រីរាជការអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៤ប័ណ្ណ

-បានធ្វើបច្ចុប្បន្នភាពដំឡើនស្ថិតិសមត្ថភាពជំនាញរបស់មន្ត្រីរាជការប្រចាំឆ្នាំ និងធ្វើដំឡើនមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឆ្នាំ២០២២

-បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្របនឹងដំណាក់កាលថ្មី

-បានបណ្តុះបណ្តាលធនធានមនុស្សក្នុងប្រទេសចំនួន០២វគ្គ មានសិក្ខាកាមចូលរួមចំនួន២២នាក់ និងក្រៅប្រទេសចំនួន០២វគ្គ មានសិក្ខាកាមចូលរួមចំនួន០៤នាក់ ព្រមទាំងសិក្ខាសាលាក្នុង និងក្រៅប្រទេសចំនួន០៣លើក មានសិក្ខាកាមចូលរួមចំនួន៩៥នាក់

-បានរៀបចំសិក្ខាសាលាស្តីពី សហគមន៍ជោគវាសនារួមកម្ពុជា-ចិន ប្រកៀកស្មាគ្នាឆ្ពោះទៅមុខក្នុងដំណើរថ្មី

-បានរៀបចំពិធីបិទវគ្គបណ្តុះបណ្តាលស្តីពី វិធីសាស្ត្របង្កើត KPI

-បានធ្វើរបាយការណ៍វាយតម្លៃការធ្វើបទបង្ហាញរបស់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភានៃវគ្គបណ្តុះបណ្តាលស្តីពី វិធីសាស្ត្របង្កើតKPIចំនួន៣៤អង្គភាព

-បានទទួលលិខិតចូលចំនួន៥៧៤ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៣៦៤ច្បាប់

-បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការងាររក្សាអនាម័យបរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ ចំណតរថយន្ត ការងារសន្តិសុខ និងសណ្តាប់ធ្នាប់ ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង

-បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ មែកឈើ និងផ្កានានាចំនួន០៦លើក

-បានចាត់ចែងកម្លាំង និងប្រើប្រាស់រថយន្តបោសសម្អាតតាមដងផ្លូវ ក្នុងបរិវេណព្រឹទ្ធសភា និងនៅជាប់របងខាងមុខព្រឹទ្ធសភា

-បានជួសជុលកែលម្អ៖ ដំបូល សំយ៉ាបពិដានបន្ទប់រង់ចាំនៅស្ពាបខាងកើត-ខាងលិចសាលប្រជុំពេញអង្គ និងនាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ, បំពាក់ផ្ទាំងគំនូរនៅសាលសាឡុងធំ និងសាលអចិន្ត្រៃយ៍, បន្ទប់ទឹកនៅតាមអគារជប៉ុនទី១, ទី២ និងអគារABC, ខាត់ លាបខ្លោងទ្វារចូល P1 និងរបងខាងមុខព្រឹទ្ធសភា, ប្តូរកែងអ្នូតូទ្វារដែកនៅអគ្គាធិការដ្ឋាន និងនាយកដ្ឋានហិរញ្ញវត្ថុ

-បានជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក, ត្រួតពិនិត្យសត្វកណ្តៀរ, ផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម, បិទលេខកូដសម្ភារសារពើភណ្ឌ ព្រមទាំងបានប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៧៨គ្រឿង/លើក

-បានប្រចាំការត្រួតពិនិត្យម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំ និងការប្រើប្រាស់ទឹក ភ្លើង ក្រោយម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាកចំនួន៤៨លើក

-បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែវិច្ឆិកា ឆ្នាំ២០២២ ទូលថ្វាយ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែវិច្ឆិកា ឆ្នាំ២០២២ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័ននានា។

### ៤.២-ការងារសេវាច្បាប់៖

-បានទទួលសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់ ពីរាជរដ្ឋាភិបាល

-បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស សារាចរណែនាំ របាយការណ៍ សេចក្តីជូនដំណឹង និងលិខិតផ្សេងៗចំនួន៣៨៦ច្បាប់

-បានធ្វើកំណត់បង្ហាញរបាយការណ៍សវនកម្មចំនួន១១ច្បាប់

-បន្តចងក្រងបញ្ជីអត្ថបទច្បាប់ ដែលព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់តាមឆ្នាំ និងនីតិកាលនីមួយៗ។

### ៤.៣-ការងារស្រាវជ្រាវ៖

-បានផលិតឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់

-បានសិក្សាស្រាវជ្រាវ ចងក្រង និងផលិតឯកសារលើប្រធានបទចំនួន៣០ប្រធានបទ

-បានតាមដាន និងចងក្រងក្របខណ្ឌគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម (ឆ្នាំ២០១៥-២០២៥)

-បានផលិត និងផ្សាយព្រឹត្តិបត្រស្រាវជ្រាវសេដ្ឋកិច្ច សង្គម ស្តីពី វិបត្តិថាមពលសកលឆ្នាំ២០២២

- បានផលិតព័ត៌មានច្បាប់ជាតិ និងអន្តរជាតិចំនួន៨៧អត្ថបទ

- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចប្រចាំខែវិច្ឆិកា ឆ្នាំ២០២២ ចំនួន០៤ច្បាប់។

**៤.៤-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

- បានរៀបចំទិន្នន័យច្បាប់ (Legal Database) របស់ព្រឹទ្ធសភា

- បានធ្វើបច្ចុប្បន្នភាពគេហទំព័រ (Laws.gov.kh) ប្រមូលព័ត៌មានទាក់ទងនឹងច្បាប់ អនុក្រឹត្យ ព្រះរាជក្រឹត្យ និងច្បាប់ដែលបានធ្វើវិសោធនកម្ម និងអនុម័តរួចចំនួន០២លើក

- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi, ជួសជុលកុំព្យូទ័រ និងដាក់កម្មវិធីកម្ចាត់មេរោគ Update Files Antivirus ព្រមទាំងបានដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មានចំនួន៥៩គ្រឿង។ បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភាចំនួន២២៦ប្រធានបទ

- បានបន្តបំពាក់ឧបករណ៍អេឡិចត្រូនិចមានដូចជា កុំព្យូទ័រយួរដៃ កុំព្យូទ័រលើតុ និងIpad ជូនសមាជិកព្រឹទ្ធសភា និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៣គ្រឿង

- បានទទួលសៀវភៅច្បាប់ ឯកសារ និងសៀវភៅជំនាញផ្សេងៗចំនួន១០០ក្បាល ព្រមទាំងបានបោះត្រា ចុះបញ្ជីសៀវភៅ អ៊ុតក្របសៀវភៅ បញ្ជូនសៀវភៅទៅសេវាអ្នកអាន បិទប័ណ្ណខ្ចី និងសងសៀវភៅចំនួន១២៦ក្បាល

- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃចំនួន៣៨លើក និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន១៧លើក

- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុង Chanel Telegram ព័ត៌មានប្រចាំថ្ងៃចំនួន១,៦៥៤ប្រធានបទ

- បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតខ្សែវីដេអូ ការបោះពុម្ព និងការថតផ្សព្វផ្សាយអំពីសម័យប្រជុំព្រឹទ្ធសភាឱ្យបានលឿនល្អ និងរលូនៗ

**៤.៥-ការងារពិធីការ៖**

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន១៨លើក

- បានកសាងជំនួយស្មារតី និងធ្វើលិខិតថ្លែងអំណរគុណ ជូនថ្នាក់ដឹកនាំព្រឹទ្ធសភាចំនួន១៨លើក

- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន១៣ច្បាប់

-បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំខែវិច្ឆិកា ឆ្នាំ២០២២ ចំនួន ០១ច្បាប់។

**៤.៦-ការងារអគ្គាធិការដ្ឋាន៖**

-បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្ដល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែវិច្ឆិកា ឆ្នាំ២០២២ ចំនួន១៩លើក

-បានជួបប្រជុំពិភាក្សាការងារជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងធ្វើរបាយការណ៍ស្ដីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្ដីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារតាមអគារ និងសណ្ដាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា

-បានចុះត្រួតពិនិត្យជាក់ស្ដែងតាមនាយកដ្ឋាន ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមានដែលអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បញ្ជូនមកនាយកដ្ឋានគ្រប់គ្រងផ្ទៃក្នុងនៃអគ្គាធិការដ្ឋានរៀងរាល់ថ្ងៃ និងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ

-បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមានប្រចាំថ្ងៃចំនួន៣២លើក ប្រចាំសប្ដាហ៍ចំនួន ០៤លើក និងប្រចាំខែវិច្ឆិកា ឆ្នាំ២០២២

-បានធ្វើរបាយការណ៍ស្ដីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្ដល់សេវាប្រចាំខែវិច្ឆិកា ឆ្នាំ២០២២។

**II-លទ្ធផលការងារគាំទ្រលើមុខងារទាំង៥៖**

-បានពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៥២ច្បាប់

-បានធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៣៧ច្បាប់ ស្មើនឹង៨៩នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន០២ច្បាប់ ស្មើនឹង០២នាក់

-បានសួរសុខទុក្ខនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៥លើក

-បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគចំនួន២១០លីត្រ ជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានផ្ដល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន២២០លើក

-បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ

ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៨៧សំណើ

-បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន៣៧លើក មានអ្នកចូលរួមចំនួន១,២៦៧នាក់

-បានថតចម្លងឯកសារចំនួន៧,០១៣ច្បាប់ និងចងក្រងធ្វើជាសៀវភៅចំនួន៦៣ក្បាល អស់ក្រដាសចំនួន៧៨,៩១១សន្លឹក

-បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន ១៩៨លើក ស្មើនឹង៤៦៥នាក់

-បានតុបតែងលម្អ តាំងពិព័រណ៍រូបភាព ធ្វើហ្វុងអក្សរ និងចងបដា ពាក្យស្លោកចំនួន១១លើក

-បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានព្រឹទ្ធសភាចំនួន១០លើក

-បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube និងFacebook ចំនួន ២៦៦លើក

-បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន១៦លើក។

## II-**ទិសដៅការងារខែធ្នូ ឆ្នាំ២០២២**

-ត្រៀមបត់បែនដើម្បីប្រឈមនឹងការគំរាមកំហែងថ្មីៗ កូវីដ-១៩ ជំងឺរាតត្បាតថ្មី គ្រោះធម្មជាតិ

-បន្តប្រឈមការប្រែប្រួលអាកាសធាតុ ផលវិបាកសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន សភាពការណ៍តំបន់ និងពិភពលោក ដូចជាអំពើភេរវកម្ម អំពើឧក្រិដ្ឋកម្ម ការវាយប្រហារ និងជំរិតខាងបច្ចេក-វិទ្យាព័ត៌មាន

-បន្តយកចិត្តទុកដាក់បរិស្ថាន អនាម័យ សួនច្បារ សំរាម ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បច្ចេកទេស បច្ចេកវិទ្យា អគារការិយាល័យ សុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

-លើកកម្ពស់សមត្ថភាពប្រើប្រាស់ និងថែទាំបច្ចេកទេស គ្រប់គ្រងការប្រើប្រាស់កម្លាំង និងបច្ចេក-វិទ្យាព័ត៌មានឱ្យបានសមស្របតាមការប្រែប្រួល និងតម្រូវការថ្មី ដោយធានាបានសន្តិសុខ សុវត្ថិភាព វឌ្ឍនភាព និងនិរន្តរភាព

**-បន្តប្រក្រតីភាព និងនិរន្តរភាពការងាររបស់ស្ថាប័នលើគ្រប់វិស័យ និងមុខងារទាំង៥ ក្នុងលក្ខណៈបត់បែន ទន់ភ្លន់ក្នុងសភាពការណ៍ចល័ត ដើម្បីធានាបរិមាណ និងគុណភាពការងារ**

+ជានានិរន្តរភាព ប្រក្រតីភាព ប្រសិទ្ធភាព សុវត្ថិភាពនៃការដឹកនាំ និងគ្រប់គ្រងប្រព័ន្ធការងាររដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស ព័ត៌មាន សន្តិសុខ បច្ចេកវិទ្យា នីតិវិធី ពិធីការ ការស្រាវជ្រាវ ទំនាក់ទំនងក្នុង-ក្រៅស្ថាប័ន និងក្នុង-ក្រៅប្រទេស ព្រមទាំងជំនួយកិច្ចសហប្រតិបត្តិការនានា

+ទ្រទ្រង់ដំណើរឆ្ពោះទៅកាន់មូលដ្ឋានរបស់សមាជិកព្រឹទ្ធសភា ក្នុងរយៈពេលវិស្សមកាល (ចាប់ពីខែធ្នូ ឆ្នាំ២០២២ ដល់ខែកុម្ភៈ ឆ្នាំ២០២៣)

+បង្កើនគុណភាព និងប្រសិទ្ធភាពផ្តល់សេវាជូនសមាជិកព្រឹទ្ធសភា ឱ្យបានល្អប្រសើរ និងគ្រប់ជ្រុងជ្រោយក្នុងដំណើរចុះទៅមូលដ្ឋាន និងជួបសវនាការជាមួយក្រសួង ស្ថាប័ននានា។

**១- មុខងារនីតិកម្ម**

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងបើកសម័យប្រជុំពេញអង្គលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤ មានរបៀបវារៈដូចខាងក្រោម៖

១-សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣

២-សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើ៖

៣.១-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មនៃអនុសញ្ញាស្តីពី អាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយបន្ថែមមាត្រា៣ស្ទួន

៣.២-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥០(ក)នៃអនុសញ្ញាស្តីពី អាកាសចរណ៍ស៊ីវិលអន្តរជាតិ

៣.៣-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥៦ នៃអនុសញ្ញាស្តីពី អាកាសចរណ៍ស៊ីវិលអន្តរជាតិ

- ត្រៀមរៀបចំជូនគណៈកម្មការទី២ និងទី៩ព្រឹទ្ធសភា ប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់

- ត្រៀមរៀបចំជូនគណៈកម្មការពិសេស និងនីតិវិធីការងារ ដើម្បីរៀបចំសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

**២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបសវនាការពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា

- ត្រៀមរៀបចំពិធីជំនួបពិភាក្សាការងារជូនសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការស្តារនីតិសម្បទាឡើងវិញ។

### ៣- មុខងារតំណាង

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញចុះទៅប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន និងអាជ្ញាធរដែនដី ព្រមទាំងចូលរួមពិធីសាសនា និងពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា

-ត្រៀមរៀបចំជូនគណៈកម្មការទី១ព្រឹទ្ធសភា ជួបប្រជុំពិភាក្សាការងារជាមួយគណៈកម្មការទី១ រដ្ឋសភា អង្គការការីតាសកម្ពុជា និងក្រុមហ៊ុនសាប៊ូក្និន ដើម្បីរៀបចំពិធីអបអរសាទរទិវាសិទ្ធិមនុស្ស១០ធ្នូ ខួបលើកទី៧៤

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកព្រឹទ្ធសភា អញ្ជើញចូលរួមទិវាសិទ្ធិមនុស្ស ១០ធ្នូ ខួបលើកទី៧៤

-ត្រៀមរៀបចំជូនសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២, ទី៤, ទី៥ និងទី៦ ចុះជួបសំណេះសំណាល ជាមួយសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ នៅខេត្តឧត្តរមានជ័យ ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តតាកែវ ខេត្តកំពត និងខេត្តកែប

-ត្រៀមរៀបចំជូនក្រុមសមាជិកាព្រឹទ្ធសភា ចុះជួបសំណេះសំណាលជាមួយក្រុមសមាជិកា ឃុំ-សង្កាត់ នៅខេត្តសៀមរាប

-ត្រៀមរៀបចំជូនសមាជិកព្រឹទ្ធសភា ក្រុមទី៤ ដឹកនាំដោយឯកឧត្តម **ម៉ុម ជឹមហ៊ុយ** បើកកិច្ចប្រជុំផ្ទៃក្នុងក្រុម ដើម្បីស្តាប់បទបង្ហាញរបស់អគ្គនាយកដ្ឋានស្រាវជ្រាវ និងពិនិត្យពិភាក្សាលើឯកសារពាក់ព័ន្ធផ្សេងៗ ដើម្បីត្រៀមចូលរួមបន្តសម័យប្រជុំលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤

-ត្រៀមរៀបចំវេទិកាជាមួយសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ទើបនឹងជាប់ឆ្នោតថ្មីនៃភូមិភាគទី៤ នៅខេត្តសៀមរាប (ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២២)។

### ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំក្នុងពិធីជំនួបជាមួយឥស្សរជនជាន់ខ្ពស់បរទេស និងអង្គទូតនានា នៃប្រទេសជាមិត្ត

-ត្រៀមទទួលគណៈប្រតិភូបេសកកម្មសុឆន្ទៈនៃសភាប្រេីកាសាបារាំង (APF) (ថ្ងៃទី០១-០៣ខែធ្នូ ឆ្នាំ២០២២)

-ត្រៀមរៀបចំពិធីបំពាក់គ្រឿងឥស្សរិយយសរបស់គណៈប្រតិភូបេសកកម្មសុឆន្ទៈនៃសភាប្រើភាសាបារាំង(APF) ជូនឯកឧត្តមប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា

-ត្រៀមចូលរួមមហាសន្និបាត (APF), (IPU) និងកិច្ចប្រជុំពាក់ព័ន្ធ

-ត្រៀមទស្សនកិច្ចសិក្សានៅព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋបារាំង

-ផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា កម្មវិធីជំនួប កម្មវិធីផ្លូវការ ការស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ អភិវឌ្ឍស្ថាប័ន ការបណ្តុះបណ្តាលធនធានមនុស្សតាមការកំណត់ និងក្នុងលក្ខណៈបត់បែនជាការតម្រូវនៃបរិបទកូវីដ-១៩

-តាមដានបញ្ហាចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU) ជាមួយឥណ្ឌា និងប៉ាគីស្ថាន ការអនុវត្តកម្មវិធីវិទ្យាស្ថានក្រសួងការបរទេស មជ្ឈមណ្ឌលសភាអាស៊ី(PCA) និងវិទ្យាស្ថានចក្ខុវិស័យអាស៊ី

-ត្រៀមចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU) ជាមួយអង្គការ KPI

-ជំរុញកម្មវិធីបណ្តុះបណ្តាលមន្ត្រីក្នុង និងក្រៅប្រទេស តាមកម្មវិធីសហប្រតិបត្តិការជាមួយភាគីជាមិត្ត (PCA, AVI) និងដៃគូផ្សេងៗទៀត

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ និងដោយផ្ទាល់

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្រ្តថវិកាតិច សកម្មភាពច្រើន

-សហការជាមួយដៃគូសំខាន់ៗ អនុវត្តកម្មវិធីសហប្រតិបត្តិការ និងបន្តស្វែងរកជំនួយសម្រាប់អភិវឌ្ឍន៍ស្ថាប័ន ធនធានមនុស្ស និងបច្ចេកវិទ្យាព័ត៌មាន។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-បញ្ចប់ការបំពេញឯកសារប្រកាសទ្រព្យសម្បត្តិសម្រាប់ឆ្នាំ២០២៣ ឱ្យបានទាន់ពេលវេលា

-ត្រៀមធ្វើរបាយការណ៍ចន្លោះសម័យប្រជុំព្រឹទ្ធសភា លើកទី៩ និងលើកទី១០ នីតិកាលទី៤

-គ្រប់អង្គភាពពាក់ព័ន្ធត្រៀមធ្វើរបាយការណ៍តាមវិស័យ និងរបាយការណ៍ស្តីពី សកម្មភាពការងារ

របស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំឱ្យបានល្អ និងទាន់ពេលវេលា

-ត្រៀមរបាយការណ៍ទូទាត់ថវិកាព្រឹទ្ធសភាឆ្នាំ២០២២ និងការបែងចែកឥណទានឆ្នាំ២០២៣ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-បន្តតាមដានជាមួយស្ថានទូតចិន ស្ថានទូតវៀតណាម និងពាណិជ្ជកម្មចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា គម្រោងស្នើកសាងអគារថ្មី១ខ្នង និងការស្វែងរកជំនួយពីរដ្ឋាភិបាលនៃប្រទេសជាមិត្តសម្រាប់នីតិកាលថ្មីខាងមុខ

-ការបើកប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗរបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការសម្រាប់ខែធ្នូ ឆ្នាំ២០២២ និងប្រាក់ឧបត្ថម្ភផ្សេងៗ ឱ្យបានទាន់ពេលវេលា

-ត្រៀមរៀបចំបែបបទដំឡើងប្រាក់បំណាច់មុខងារដល់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាសម្រាប់ឆ្នាំ២០២៣

-បន្តវិចារណកម្មថវិកា៖ សន្សំសំចៃ និងអាទិភាពចំពោះតែការងារចាំបាច់បន្ទាន់ និងប្រញាប់បំផុត៖

+ការវិនិយោគលើវិស័យបច្ចេកវិទ្យាព័ត៌មាន និងវិស័យបច្ចេកទេស គឺជាស្នូលសំខាន់នៃការអភិវឌ្ឍស្ថាប័ន និងការលើកកម្ពស់សមត្ថភាពលើគ្រប់វិស័យ ព្រមទាំងជំនាញរបស់មន្ត្រីបុគ្គលិក

+ចាប់ផ្តើមអនុលោមតាមបរិបទបរិស្ថានទំនើប ដែលប្រឆាំងការប្រែប្រួលអាកាសធាតុ (ការគ្រប់គ្រងសំរាម និងផ្លាស្ទិក)

-ត្រៀមរៀបចំឯកសារគោលស្តីពី តួនាទី ភារកិច្ច របស់នាយកដ្ឋាន និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកសារពិពណ៌នាការងារ និងបញ្ជាក់ពីសមត្ថភាពធ្វើការងាររបស់មន្ត្រីរាជការ

-ត្រៀមរៀបចំគោលការណ៍ គោលនយោបាយថ្មី ស្របតាមដំណើរការងារ និងស្ថានភាពជាក់ស្តែង ចំនួន០៣គឺ៖

១-គោលការណ៍ស្តីពី ការផ្តល់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការមានស្នាដៃឆ្នើម
២-គោលការណ៍ស្តីពី ការវាយតម្លៃការបំពេញការងាររបស់មន្ត្រីរាជការ
៣-គោលនយោបាយស្តីពី ការគ្រប់គ្រងធនធានមនុស្ស

-ត្រៀមធ្វើជំរឿនសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ តម្រូវការ និងការប្រឈម

-ត្រៀមធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា លើកកម្ពស់សមត្ថភាពដឹកនាំ

និងគ្រប់គ្រងគ្រប់កម្រិត គ្រប់វិស័យ ពង្រឹងពង្រីកសមត្ថភាពបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងសាធារណៈ

-ធ្វើបច្ចុប្បន្នភាពផែនការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សរយៈពេល១០ឆ្នាំ (២០២២-២០៣០) របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ធ្វើសម្រង់តម្រូវការអភិវឌ្ឍន៍សមត្ថភាពរបស់មន្ត្រីរាជការប្រចាំឆ្នាំ២០២៣

-កសាងផែនការបណ្តុះបណ្តាលសម្រាប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឆ្នាំ២០២៣

-ត្រៀមបើកវគ្គបណ្តុះបណ្តាលលើមុខជំនាញដែលជាតម្រូវការចាំបាច់របស់ស្ថាប័ន

-ត្រៀមបញ្ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមវគ្គបណ្តុះបណ្តាលនៅប្រទេសឥណ្ឌា

-បន្តសិក្សាគម្រោង និងប្លង់សាងសង់សាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ថ្មី និងប្លង់សាងសង់របងថ្មីខាងមុខព្រឹទ្ធសភា

-បន្តការងារជួសជុលថែទាំអគារ ខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា អគារបណ្ណាល័យ គូសគំនូសចរាចរ ចំណតយានយន្ត និងជួសជុលផ្លាស់ប្តូរគ្រឿងបរិក្ខារផ្សេងៗនៅតាមអគារ

-កែលម្អបរិស្ថាន និងអនុវត្តការងារជួសជុលផ្សេងៗក្នុងករណីចាំបាច់ ពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ និងវិន័យការងារ

-ត្រៀមរៀបចំផែនការការងារសម្រាប់ការត្រៀមទទួលនីតិកាលទី៥របស់ព្រឹទ្ធសភា និងការត្រៀមជាបណ្តើរៗ ការរៀបចំជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារការិយាល័យធ្វើការ រួមទាំងបំពាក់សម្ភារៈ

-ត្រៀមធ្វើរបាយការណ៍បូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣

-ត្រៀមប្រជុំវាយតម្លៃស្តីពី ការតែងតាំងមុខតំណែងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បង្កើនគុណភាពនៃការថត និងផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារអេឡិចត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ព្រមទាំងការចូលរួមវគ្គផ្សេងៗ រៀបចំដោយសភានៃប្រទេសជាមិត្ត (ឥណ្ឌា...)

-ត្រៀមរៀបចំផលិតវីដេអូព័ត៌មានរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ការបោះពុម្ពទិនានុលេខន៍ ប្រតិទិន ប័ណ្ណរថយន្ត ត្រូវធានាគុណភាព និងបរិមាណសមស្រប

តាមកម្មវិធីបុណ្យជាតិ បុណ្យប្រពៃណី និងកម្មវិធីផ្សេងៗទៀតត្រូវបានការអនុវត្តឱ្យបានទាន់ពេលវេលា

-ត្រៀមធ្វើសារលិខិតជូនពរជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងឱកាសចូលឆ្នាំសាកល។

## IV-សេចក្តីសន្និដ្ឋាន

ក្នុងខែវិច្ឆិកានេះ ព្រឹទ្ធសភា និងប្រជាជនកម្ពុជាទូទាំងប្រទេស បានចូលរួមអបអរសាទរ និងសម្តែងការសប្បាយរីករាយដែលព្រះរាជាណាចក្រកម្ពុជា ទទួលបានជោគជ័យយ៉ាងត្រចេះត្រចង់ក្នុងការរៀបចំកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និងទី៤១ ព្រមទាំងកិច្ចប្រជុំមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៤៣។

ស្ថិតក្នុងបរិបទនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក៏បានផ្តោតការយកចិត្តទុកដាក់ផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា ជួបសវនាការ ជាមួយគណៈប្រតិភូជាន់ខ្ពស់បណ្តាប្រទេសនានា ព្រមទាំងចូលរួមកិច្ចប្រជុំអន្តរជាតិបានល្អប្រសើរ ជាពិសេសការរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ចូលរួមក្នុងមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៤៣ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ។

ចំពោះមុខងារតំណាង អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក៏បានរួមចំណែករៀបចំ និងផ្តល់សេវាចូលរួមក្នុងពិធីបុណ្យជាតិ ការចុះបំពេញការងារតាមមូលដ្ឋាន និងចូលរួមពិធីផ្សេងៗជូនសមាជិកព្រឹទ្ធសភា ទទួលលទ្ធផលល្អ និងទាន់ពេលវេលា។

មន្ត្រីរាជការទាំងអស់ ត្រូវបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការនានា ដែលរាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល បានដាក់ចេញជាពិសេសវិធានការ "៣ការពារ ៣កុំ" និងការចាក់វ៉ាក់សាំងដូសជំរុញឱ្យបានគ្រប់ៗគ្នាកុំបីខាន ដើម្បីការពារមិនឱ្យជំងឺកូវីដ-១៩ អាចឆ្លងរាលដាលជាថ្មីទៀតបាន។

ថ្ងៃពុធ ១៤កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២

**អគ្គលេខាធិការ**

អ៊ុំ សារឹទ្ធ